មាត្រា១១ : អគ្គលេខាធិការដ្ឋានមានភារកិច្ចជាសេនាធិការ ឱ្យគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយលើការងារ :

- ធានានិរន្តរភាពនៃដំណើរការរដ្ឋបាលរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។
- សិក្សាស្រាវជ្រាវតំបន់ងាយរងគ្រោះដោយទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ ភ្លើងឆេះព្រៃ ជំងឺរាតត្បាត និងមុខសញ្ញាគ្រោះថ្នាក់ដទៃទៀត ដោយរៀបចំផែនការ ត្រៀមបង្ការ ឆ្លើយតបសង្គ្រោះបន្ទាន់ ។
- ណែនាំការងារ ជំនាញបច្ចេកទេសដល់លេខាធិការដ្ឋាន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ សហគមន៍ជួយសង្គ្រោះ ដើម្បីជាមូលដ្ឋានក្នុងការប្រមូលទិន្នន័យគ្រោះមហន្តរាយ សំរាប់ធ្វើការវាយតំលៃប៉ាន់ស្មាន អំពីការខូចខាត និងតំរូវការ និងរៀបចំកម្មវិធីស្តារ និងកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ ដែលខូចខាត ដោយសំរបសំរួលការងារជាមួយស្ថាប័ននានា ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ដែលពាក់ព័ន្ធ ។
- លើកផែនការ បណ្តុះបណ្តាលជំនាញបច្ចេកទេស ដល់បុគ្គលិកគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់កណ្តាល ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ និងសហគមន៍ជួយសង្គ្រោះ ក្នុងក្របខ័ណ្ឌបណ្តុះបណ្តាលក្នុងប្រទេស និងក្រៅប្រទេស ។
- សំរបសំរួលការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ សមាគមជាតិ អាជ្ញាធរដែនដី ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ដើម្បីជំលៀសប្រជាជន

ងាយរងគ្រោះ ទៅទីសុវត្ថិភាព ការពារសន្តិសុខ អប់រំសាធារណៈ ឆ្លើយតបសង្គ្រោះបន្ទាន់ និងរៀបចំកម្មវិធីផ្សេង ១ ។

- លើកយោបល់រាល់លិខិតស្នាមពាក់ព័ន្ធ ការងារគ្រប់គ្រងគ្រោះមហន្តរាយ និងលិខិតព្រមព្រៀង បូកសរុបរបាយការណ៍ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ មាននាយកដ្ឋានចំនួន ៥ ដូចមានក្នុងមាត្រាខាងក្រោម :

មាត្រា ១២ : នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានភារកិច្ច :

- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាល របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។
- សរុបរបាយការណ៍ការងារ និងសកម្មភាពផ្សេង១ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។
- គ្រប់គ្រងរដ្ឋបាល ផ្នែកមន្ត្រីរាជការ របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ។
- ប្រមូលផ្តុំគំរូវការ លើកគំរោងថវិកា ធ្វើកម្មវិធីចំណាយ និងតាមដានរំលឹកពីការប្រតិបត្តិ ។
- សំរបសំរួលជំពូក ថវិកា និងរាល់ចំណាយ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។
- គ្រប់គ្រងអចលនទ្រព្យ ចលនទ្រព្យ សន្និធិសំភារៈ និង បញ្ជីសារពើភ័ណ្ឌ ។

មាត្រា ១៣: នាយកដ្ឋាន ពត៌មាន និងទំនាក់ទំនង មានភារកិច្ច :

- ធ្វើការតាមដាន ពត៌មានអាកាសធាតុ ស្ថានភាពឧតុនិយម ជលសាស្ត្រ ។
- និពន្ធ និងចងក្រងដំណើងអត្ថបទ ស្តីពីគ្រោះមហន្តរាយ ។
- ចេញផ្សាយនូវពត៌មាន ស្តីពីគ្រោះមហន្តរាយផ្សេង១ក្នុង និងក្រៅប្រទេស តាមរយៈព្រឹត្តិប័ត្រ និងប្រព័ន្ធផ្សាយពត៌មាន ។
- ផលិតផ្ទាំងរូបភាព សៀវភៅរូបថត ពីគ្រោះមហន្តរាយ ។
- រៀបចំរបាយការណ៍ ស្តីពីស្ថានភាពជលសាស្ត្រ ឧតុនិយម ដោយសហការជាមួយក្រសួងស្ថាប័នជំនាញ និងប្រកាសជូនដំណើងជាមុននូវគ្រោះអាសន្ន កង្វះខាត និងវិធានការណ៍ ។
- ទំនាក់ទំនងការងារគ្រោះមហន្តរាយ ជាមួយបរទេស និងអង្គការអន្តរជាតិ ។

មាត្រា ១៤ : នាយកដ្ឋាន ឆ្លើយតបសង្គ្រោះបន្ទាន់ និងស្តារឡើងវិញ មានភារកិច្ច :

- រៀបចំ បង្កើតឡើងនូវចនាសម្ព័ន្ធបញ្ជាការ ក្នុងសកម្មភាពសង្គ្រោះបន្ទាន់ ស្របតាមគោលនយោបាយជាតិគ្រប់គ្រងគ្រោះមហន្តរាយ នៅពេលទំទួលបានពត៌មាន ព្យាករណ៍ស្តីពីគ្រោះមហន្តរាយ ។

- រៀបចំផែនការត្រៀមបង្ការ កាត់បន្ថយ សង្គ្រោះបន្ទាន់ កម្មវិធីស្តារលទ្ធភាពពលកម្ម និង ការស្តារឡើងវិញ ។
- សំរបសំរួលជាមួយក្រសួងពាក់ព័ន្ធ ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ស្រាវជ្រាវមុខសញ្ញាគ្រោះថ្នាក់ សេវាកម្ម សង្គ្រោះបន្ទាន់ ការពារសុវត្ថិភាព សន្តិសុខ ជំលៀស ទីជំរក ។
- ចុះស្រង់ស្ថិតិការខូចខាត និងសេចក្តីត្រូវការ និងដឹកនាំប្រតិបត្តិការពេលមានគ្រោះអាសន្ន ។

មាត្រា ១៥ : នាយកដ្ឋាន ត្រៀមរៀបចំ និងបណ្តុះបណ្តាលមានភារកិច្ច :

- ត្រៀមរៀបចំមូលដ្ឋានសំភារៈ ត្រៀមផ្គត់ផ្គង់ផ្សេងៗ សំរាប់ឆ្លើយតបសង្គ្រោះបន្ទាន់ ពេលមានគ្រោះអាសន្ន ។
- កសាងផែនការ កម្មវិធីបណ្តុះបណ្តាលធនធានមនុស្ស ដែលបំរើឱ្យការងារគ្រប់គ្រង គ្រោះមហន្តរាយថ្នាក់ជាតិ មូលដ្ឋាន ។
- ជ្រើសរើសបេក្ខជន ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស ។
- អប់រំ ផ្សព្វផ្សាយ អំពីការងារត្រៀមរៀបចំបង្ការគ្រោះមហន្តរាយ ដល់សហគមន៍ មូលដ្ឋាន និងប្រជាជនរងគ្រោះ ។
- ចែកផ្សាយឯកសាររូបភាពដែលពាក់ព័ន្ធដល់ការងារបង្ការ និងកាត់បន្ថយគ្រោះមហន្តរាយ ។

មាត្រា ១៦: នាយកដ្ឋាន សំរបសំរួលការងារ ឧបទ្ទវហេតុ យន្តហោះ នាវា មានភារកិច្ច :

- សំរបសំរួលការងារជាមួយ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាពស្របទៅតាមនិតិវិធីដែលបានរៀបចំឡើង ។
- រៀបចំគំរោងផែនការជូន អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរៈភូមិន្ទ ក្នុងការ ប្រើប្រាស់មធ្យោបាយ និងកំលាំងអន្តរាគមន៍រុករក និងសង្គ្រោះ ។
- ទទួល និងបញ្ជូនពត៌មាន ស្តីពីឧបទ្ទវហេតុយន្តហោះ នាវា និងស្នើសុំគោលការណ៍ អនុវត្តបទបញ្ជា និងការណែនាំពីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ទាក់ទង នឹងការសំរបសំរួល រុករក និងសង្គ្រោះ ។
- ធ្វើសេចក្តីប្រកាសជាផ្លូវការ ពីទីកន្លែងកើតឧបទ្ទវហេតុយន្តហោះ នាវា នៅពេល ពត៌មាន ជាក់លាក់ត្រូវបានផ្ទៀងផ្ទាត់ ។
- រៀបចំបែបបទ សំរបសំរួលជាមួយប្រទេសជិតខាង ដើម្បីរួបសហការដោះស្រាយការងារ រុករក និងសង្គ្រោះ ស្របទៅតាមកិច្ចព្រមព្រៀងស្តីពីការសំរបសំរួលរុករក និងសង្គ្រោះ ។

- សហការជាមួយមជ្ឈមណ្ឌល សំរបសំរួល សង្គ្រោះ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល កំណត់បេសកកម្ម រុករក និងសង្គ្រោះ ។

ជំពូកទី ៥

ក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួង ស្ថាប័ន

មាត្រា ១៧ : ក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងស្ថាប័ន ត្រូវបានបង្កើតឡើងដោយ ក្រសួងស្ថាប័ននីមួយៗផ្ទាល់ ដើម្បីបង្កើនការលើកកំពស់ស្មារតី ភាពម្ចាស់ការចូលរួមដោះស្រាយគ្រោះមហន្តរាយ និងមានភារកិច្ចទទួលខុសត្រូវ ដើម្បីធ្វើការសំរបសំរួល រាល់សកម្មភាពក្នុងការត្រៀមរៀបចំ ឆ្លើយតបគ្រោះមហន្តរាយ និងស្តារឡើងវិញ ។

ជំពូកទី ៦

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ខេត្ត-ក្រុង

មាត្រា ១៨: នៅតាមខេត្ត-ក្រុងនីមួយៗមាន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ខេត្ត-ក្រុង ដែលមានសមាសភាព :

- អភិបាល ខេត្ត-ក្រុង ជាប្រធាន
- អភិបាលរង ខេត្ត-ក្រុង ជាអនុប្រធាន
- ប្រធាន មន្ទីរជុំវិញ ខេត្ត-ក្រុង
 និង នាយកសាខាកាកបាទក្រហម ខេត្ត-ក្រុង ជាសមាជិក

មាត្រា ១៩: គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ខេត្ត-ក្រុង មានភារកិច្ច :

- អនុវត្តគោលនយោបាយជាតិ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ។
- រៀបចំធ្វើការណែនាំ និងគាំទ្រដល់សកម្មភាពគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ស្រុក-ខណ្ឌ ។
- ផ្តល់យោបល់ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ចំពោះសកម្មភាពរបស់ស្ថាប័នពាក់ព័ន្ធកាកបាទក្រហមកម្ពុជា ការឧបត្ថម្ភរបស់អង្គការជាតិ និងអន្តរជាតិ ដែលចូលរួមទប់ស្កាត់ ត្រៀមរៀបចំសង្គ្រោះបន្ទាន់ និងស្តារឡើង វិញ ។
- ធ្វើរបាយការណ៍ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ស្តីពីការខូចខាត និងធ្វើសំណើសុំឧបត្ថម្ភថវិកា សំភារៈបរិក្ខារមធ្យោបាយ និងកំលាំងអន្តរាគមន៍ សំរាប់ដោះស្រាយក្នុងពេលមានគ្រោះមហន្តរាយ ។

- អនុវត្តកម្មវិធីបណ្តុះបណ្តាល ដើម្បីពង្រឹងជំនាញបច្ចេកទេស ដល់មន្ត្រីរាជការ ក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ និងអនុវត្តកម្មវិធីអប់រំ ជាសាធារណៈនៅក្នុងសហគមន៍ ។

មាត្រា ២០ : គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង មានលេខាធិការដ្ឋាន ជាសេនាធិការសំរាប់ធានានិរន្តរភាពការងារ ដែលដឹកនាំដោយនាយខុទ្ទកាល័យសាលាខេត្ត-ក្រុង ធ្វើជាលេខាអចិន្ត្រៃយ៍ និងជំនួយការ មួយចំនួន ជួយការងារ តាមការចាំបាច់ ។

ជំពូកទី ៧

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខណ្ឌ

មាត្រា ២១ : នៅតាមស្រុក-ខណ្ឌ នីមួយៗមានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ដែលមានសមាសភាព :

- អភិបាល ស្រុក-ខណ្ឌ ជាប្រធាន
- អភិបាលរង ស្រុក-ខណ្ឌ ជាអនុប្រធាន
- ប្រធានការិយាល័យជុំវិញស្រុក-ខណ្ឌ
ប្រធានអនុសាខាកាកបាទក្រហម ស្រុក-ខណ្ឌ ជាសមាជិក

មាត្រា ២២ : គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ស្រុក-ខណ្ឌ មានភារកិច្ច :

- អនុវត្តគោលនយោបាយជាតិ ដែលពាក់ព័ន្ធក្នុងការងារគ្រប់គ្រងគ្រោះ មហន្តរាយ
- ផ្តល់យោបល់ជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង អំពីស្ថានភាពថ្មីៗ ។
- ជ្រើសរើសមន្ត្រីដើម្បីចូលរួម ក្នុងវគ្គបណ្តុះបណ្តាលថ្នាក់ជាតិ រឺខេត្ត-ក្រុង ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ។
- រៀបចំ និងផ្សព្វផ្សាយពត៌មាន ដល់សាធារណជន អំពីគ្រោះមហន្តរាយ ។
- បញ្ជូនរបាយការណ៍ ស្តីពីសេចក្តីត្រូវការទៅគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង ស្តីពីការខូចខាត និងតំរូវការផ្សេងៗ ។
- ដឹកនាំប្រតិបត្តិការ ក្នុងពេលមានគ្រោះមហន្តរាយ រួមមានជំនួយសង្គ្រោះ ការជំលៀសការផ្តល់ទីជំរក និងការផ្តល់ជំនួយសុខាភិបាល ។
- បញ្ជូនរបាយការណ៍សរុប ស្តីពីប្រតិបត្តិការ ជំនួយសង្គ្រោះទៅគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ខេត្ត-ក្រុង ។

មាត្រា ២៣: គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខណ្ឌ មានលេខាធិការដ្ឋាន ជាសេនាធិការសំរាប់ធានានិរន្តរភាពការងារ ដែលដឹកនាំដោយប្រធានមន្ទីរ សាលាស្រុក-ខណ្ឌ ធ្វើជាលេខាអចិន្ត្រៃយ៍ និងជំនួយការមួយចំនួន ជួយការងារតាមការចាំបាច់ ។

ជំពូកទី ៨

អង្គភាព ត្រួតពិនិត្យ ហិរញ្ញវត្ថុ

មាត្រា ២៤ : អង្គភាព ត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ញា កំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតស្ថាប័ន ត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកា តាមបណ្តាក្រសួង ។

ជំពូកទី ៩

អវសានប្បញ្ញត្តិ

មាត្រា ២៥ : ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ការិយាល័យចំណុះបណ្តានាយកដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

មាត្រា ២៦ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ២៧ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ២៨ : អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានជំរាបជូន

សម្តេច នាយករដ្ឋមន្ត្រី

អនុប្រធានទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

ញ៉ឹម វណ្ណដា

កន្លែងទទួល:

- ក្រសួង ព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្តេច នាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ២៧
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

ឧបសម្ព័ន្ធអនុក្រឹត្យលេខ ៣០ អនក្រ.បក
ចុះថ្ងៃទី ០៩ ខែមេសាឆ្នាំ ២០០២

អង្គការលេខ
របស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ



My docu/Secretary General

ឧបសម្ព័ន្ធអនុក្រឹត្យលេខ ៣០ អនក្រ.បក

ចុះថ្ងៃទី ០៩ ខែមេសាឆ្នាំ ២០០១

អង្គការលេខ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

(គ.ជ.គ.ម NCDM)



Folder: Schedule/furniture of ncdm

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការបំពេញបន្ថែមក្រុមប្រឹក្សាកំណែទម្រង់

កងយោធពលខេមរភូមិន្ទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី .
- បានឃើញព្រះរាជក្រម លេខនស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ .
- បានឃើញព្រះរាជក្រម លេខនស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ .
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ .
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតអង្គភាពសំរាប់សំរបសំរួលបញ្ចូលកងទ័ពរំសាយ និងសមាហរណកម្ម ចូលក្នុងសង្គមជាតិ អតីតទាហានខ្មែរក្រហម .
- បានឃើញអនុក្រឹត្យ លេខ៤៤ អនក្រ.បក ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ ។

សំរេច

មាត្រា១: ត្រូវបានបំពេញបន្ថែម សមាសភាពក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ និងកែសំរួលសមាសភាពអគ្គលេខាធិការដ្ឋាន ដូចខាងក្រោម :

ក - បំពេញបន្ថែម :

១ - ឧត្តមសេនីយ៍ឯក **ចាយ សាំងយុន** រដ្ឋលេខាធិការក្រសួងការពារជាតិ ជា **អនុប្រធានអចិន្ត្រៃយ៍** ។

ខ - កែសំរួល និងបន្ថែមសមាសភាពអគ្គលេខាធិការដ្ឋាន ទទួលបន្ទុកការងារអចិន្ត្រៃយ៍ ដូចខាងក្រោម ៖

១ - កែសំរួល ឧត្តមសេនីយ៍ទោ **មាស សំអុល** នាយក នាយកដ្ឋានបុគ្គលិក ក្រសួងការពារជាតិ ជា **អគ្គលេខាធិការរង** ជំនួសឧត្តមសេនីយ៍ទោ **ពុត សំអោក** ។

២ - បំពេញបន្ថែម វរសេនីយ៍ឯក **ឈុន សារ៉ឿន** នាយករង នាយកដ្ឋានបុគ្គលិក ជា **សមាជិកអចិន្ត្រៃយ៍**

៣ -បំពេញបន្ថែម វរសេនីយ៍ឯក **ឈួម រតនា** នាយករង ទីចាត់ការបុគ្គលិក អគ្គបញ្ជាការដ្ឋាន ជា **សមាជិកអចិន្ត្រៃយ៍** ។

<u>មាត្រា២</u> ៖ សមាជិកទាំងអស់ដែលបានបំពេញបន្ថែម និងបានកែសំរួល ត្រូវចូលរួមប្រជុំការងារតាមការអញ្ជើញរបស់សហប្រធានក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ ។

<u>មាត្រា៣</u> ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័នដែលពាក់ព័ន្ធ និងសាម៉ីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ ០៣ ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...១៧៥...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសុវត្ថារា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ស ំ រេ ច

មាត្រា១ : ត្រូវបានបំពាក់មេដាយ **សុវត្ថារា** ថ្នាក់ "អស្សឫទ្ធិ" ជូនមន្ត្រីជាន់ខ្ពស់០២រូប ដែលមានស្នាដៃល្អក្នុងការដឹកនាំការងារកសិកម្មរុក្ខាប្រមាញ់ និងនេសាទ តាមកម្មវិធីនយោបាយ របស់រាជរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោម :

១ ឯកឧត្តម **អ៊ឹក សុខុន** អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ

២ ឯកឧត្តម **សៅ សាមុត** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមេសា ឆ្នាំ ២០០២

ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សំរេច

មាត្រា១ : ត្រូវបានបំពាក់ មេដាយ **ការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ចំនួន ៧៦រូប ដែលមានស្នាដៃល្អក្នុងការបំពេញការងារ តាមកម្មវិធីនយោបាយ របស់រាជរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោម :

ក. <u>មេដាយមាសការងារ ចំនួន ១០ រូប</u> :

១-	លោក ជ័យ សាវង្ស	អគ្គនាយកក្រុមហ៊ុនសម្ភារៈកសិកម្ម
២-	លោក ជា គង់	ប្រធាននាយកដ្ឋានផែនការស្ថិតិ នឹង សហប្រតិបត្តិការអន្តរជាតិ
៣-	លោក លួង តឹមប៉ោ	ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ
៤-	លោក នួន ស៊ីន	ប្រធាននាយកដ្ឋានបុគ្គលិក និង អភិវឌ្ឍន៍ធនធានមនុស្ស
៥-	លោក ស៊ូ ណៃ	ប្រធានគណៈកម្មាធិការត្រួតពិនិត្យ

៦ - លោក យូ ជ្រាវ ប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល
៧- លោក លាង សំហាត ប្រធាននាយកដ្ឋានគ្រឿងយន្តកសិកម្ម
៨- លោក ឈើវ ណាំ ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
៩- លោក នីវ ណារិន ប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់ និង នេសាទខេត្តបាត់ដំបង
១០- លោក យិន សុង ប្រធានវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ខ- មេដាយស្ពាន់ការងារ ចំនួន ១៦ រូប :

១- លោក ឌុង ប៊ុននី អនុប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ
២- លោក ឡៅ នី ប្រធាននាយកដ្ឋានផែនការស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ
៣- លោក ចាយ សាគុណ អនុប្រធាននាយកដ្ឋានផែនការស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ
៤- លោក ទូត សារាវុធ អនុប្រធាននាយកដ្ឋានផែនការស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ
៥- លោក ចាន់ សារុទ្ធ អនុប្រធាននាយកដ្ឋានបុគ្គលិក និង អភិវឌ្ឍន៍ធនធានមនុស្ស
៦- លោក សូ សីហារក្យ អនុប្រធាននាយកដ្ឋានរដ្ឋបាល
៧- លោក ស្រ៊ុន សុខុម អនុប្រធាននាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម
៨- លោក យិន ឡាត់ អធិការរងនៃអគ្គាធិការដ្ឋាន
៩- លោក អ៊ឹម ផៃ អនុប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ
១០- លោក សោម សួន អនុប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល
១១- លោក អ៊ុក ស៊ឹម អនុប្រធាននាយកដ្ឋានជលផល
១២- លោក គង់ វៀន អនុប្រធានក្រុមហ៊ុនសម្ភារៈកសិកម្ម
១៣- លោក កែប ថា អនុប្រធាននាយកដ្ឋានគ្រឿងយន្តកសិកម្ម
១៤- លោក លួត ភួង ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្តបាត់ដំបង
១៥- លោក នេត ចន្ទ័ អនុប្រធានវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
១៦- លោក ជា ជឿន អនុប្រធានក្រុមហ៊ុននិហរ័ណអហរ័ណកៅស៊ូ

គ- មេដាយសំរិទ្ធការងារ ចំនួន ៥០ រូប :

១- លោក ស៊ាង ឈឿត អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្តបាត់ដំបង
២- លោក ជិម ជឿន ប្រធានការិយាល័យរដ្ឋបាលចាត់តាំងខេត្តបាត់ដំបង
៣- លោក ប៊ូ ដុស អនុប្រធានការិយាល័យផែនការស្ថិតិខេត្តបាត់ដំបង
៤- លោក ឈូក ឯម មន្ត្រីការិយាល័យផែនការស្ថិតិ
៥- កញ្ញា យឹម សារ៉ាត់ មន្ត្រីការិយាល័យរដ្ឋបាលចាត់តាំងខេត្តបាត់ដំបង
៦- លោក សៅ ឈឹម ប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តបាត់ដំបង
៧- លោក ទិម ភាន អនុប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តបាត់ដំបង
៨- លោក ឯម រិទ្ធ អនុប្រធានការិយាល័យជលផលខេត្តបាត់ដំបង

៩-	លោក សោម សុគិ	ប្រធានស្ថានីយចិញ្ចឹមក្រពើខេត្តបាត់ដំបង
១០-	លោក ទ្រឿង វដ្ឋ	ប្រធានផ្នែកសហគមន៍នេសាទខេត្តបាត់ដំបង
១១-	លោក ខាត់ ប៊ូរិន	មន្ត្រីការិយាល័យក្សេត្រសាស្ត្រនិងកែលំអដីកសិកម្មខេត្តបាត់ដំបង
១២-	លោក ប៉ិញ ឧត្តម	អនុប្រធានការិយាល័យផ្សព្វផ្សាយកសិកម្មខេត្តបាត់ដំបង
១៣-	លោក គា ឈុន	មន្ត្រីការិយាល័យផ្សព្វផ្សាយកសិកម្មខេត្តបាត់ដំបង
១៤-	លោក តូច មុនី	អនុប្រធានការិយាល័យរុក្ខាប្រមាញ់ ខេត្តបាត់ដំបង
១៥-	លោក តុល ភន	មន្ត្រីការិយាល័យរុក្ខាប្រមាញ់ ខេត្តបាត់ដំបង
១៦-	លោក សេង យ៉ុន	ប្រធានការិយាល័យគ្រឿងយន្តកសិកម្មខេត្តបាត់ដំបង
១៧-	លោក ចាំង យូរិទ្ធ	មន្ត្រីផលិតកម្ម និង បសុព្យាបាលស្រុកមោងឬស្សីខេត្តបាត់ដំបង
១៨-	លោក ស្វាយ ពៅ	មន្ត្រីផលិតកម្ម និង បសុព្យាបាលស្រុកឯកភ្នំខេត្តបាត់ដំបង
១៩-	លោក ជួង សុភា	ប្រធានសង្កាត់នេសាទព្រែកតាចែងខេត្តបាត់ដំបង
២០-	លោក អុង អេន	ប្រធានស្ថានីយកសិកម្មបឹងរាំងខេត្តបាត់ដំបង
២១-	លោក តូច នៅ	អនុប្រធានការិយាល័យកសិកម្មស្រុកសង្កែខេត្តបាត់ដំបង
២២-	លោក សុខ ណៃ	អនុប្រធានការិយាល័យកសិកម្មស្រុកឯកភ្នំខេត្តបាត់ដំបង
២៣-	លោក ឡុង ផន	អនុប្រធានការិយាល័យកសិកម្មស្រុកបវេលខេត្តបាត់ដំបង
២៤-	លោក ផេង សុខាំ	អនុប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់ និង នេសាទរាជធានីភ្នំពេញ
២៥-	លោក ទា លាងហ៊ត	អនុប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទខេត្តកណ្ដាល
២៦-	លោក កែវ នាម	អនុប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទខេត្តកំពត
២៧-	លោក អ៊ុក សេងកន	ប្រធានការិយាល័យកសិកម្មស្រុកដង្កោរាជធានីភ្នំពេញ
២៨-	លោក នង ហួរ	ប្រធានកសិដ្ឋានចំការលើនៃនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម
២៩-	លោក មឿង ជួន	ប្រធានកសិដ្ឋានម្រេចវាលរិញនៃនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម
៣០-	លោក ចៃ ហៃ	ប្រធានមណ្ឌលអភិវឌ្ឍន៍កសិកម្មដីឥដ្ឋស្រែអំពិលនៃនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម
៣១-	លោក ហុង អុន	ប្រធានមណ្ឌលអភិវឌ្ឍន៍កសិកម្មទន្លេបាទីនៃនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម
៣២-	លោក ហ៊ី ថុន	អនុប្រធានការិយាល័យគណនេយ្យនៃនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម
៣៣-	លោក សឹម មឿន	ប្រធានការិយាល័យរដ្ឋបាល បុគ្គលិកនៃនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម
៣៤-	លោក សៅ ប៊ុត	ប្រធានស្ថានីយថ្នាំជក់នៃនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម
៣៥-	លោក ព្រឹម រិន	ប្រធានការិយាល័យរដ្ឋបាលនៃនាយកដ្ឋានជលផល
៣៦-	លោក យូ ត្រីន	អនុប្រធានការិយាល័យអធិការកិច្ចនៃនាយកដ្ឋានជលផល
៣៧-	លោក ប៊ូ សេងជី	ប្រធានអធិការកិច្ចសមុទ្រនៃនាយកដ្ឋានជលផល
៣៨-	លោក ប៉េង អាន	អនុប្រធានអធិការកិច្ចសមុទ្រនៃនាយកដ្ឋានជលផល
៣៩-	លោក ស្រី លឹមហេង	អនុប្រធានការិយាល័យអាជីវកម្មនៃនាយកដ្ឋានជលផល

៤០-	លោក សៀក ឡាយជី	ប្រធានអង្គភាពនេសាទរដ្ឋកណ្តាលស្ទឹងនៃនាយកដ្ឋានជលផល
៤១-	លោក ស្រ៊ុន ណាំ	អនុប្រធានការិយាល័យជលផលនៃមន្ទីរកសិកម្មរាជធានីភ្នំពេញ
៤២-	លោក ឡុញ សំអៃ	ប្រធានការិយាល័យរដ្ឋបាលនៃនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល
៤៣-	លោក ស៊ឹម នឹម	អនុប្រធានការិយាល័យរដ្ឋបាលនៃនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល
៤៤-	លោក គង់ វ៉ាន់ថន	ប្រធានការិយាល័យផលិតកម្មនៃនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល
៤៥-	លោក ណុំ នឹម	ប្រធានការិយាល័យរដ្ឋបាលនៃនាយកដ្ឋានរដ្ឋបាល
៤៦-	លោក គៀត សេងហុង	អនុប្រធានការិយាល័យរដ្ឋបាលនៃនាយកដ្ឋានរដ្ឋបាល
៤៧-	លោក វ៉ា ដេន	ប្រធានផ្នែករបៀបនៃការិយាល័យរដ្ឋបាល នៃនាយកដ្ឋានរដ្ឋបាល
៤៨-	លោក តេង យូម៉េង	ប្រធានការិយាល័យចាត់តាំងនៃនាយកដ្ឋានបុគ្គលិក
៥៩-	លោក ឡាយ ប៉េងឈាន	ប្រធានការិយាល័យប្រវត្តិរូបនិងនាយកដ្ឋានបុគ្គលិក
៥០-	លោក គង់ ថេត	មន្ត្រីនៃនាយកដ្ឋានបុគ្គលិក

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ៤ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៨៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

<u>សម្រេច</u>

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសេរីវឌ្ឍនការងារ** ជូនដល់អស់លោកមេភូមិចំនួន ៩៣ រូប និងជំនួយការឃុំចំនួន ១៨ រូប ក្នុងស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចកន្លងមក ដូចមានរាយនាមខាងក្រោម :

១-	លោក មួង ផ្លូន	មេភូមិ តាឯក	ឃុំតាឯក	ស្រុកខ្សាច់កណ្តាល
២-	លោក សួន ង៉ុក	មេភូមិ ទ្រាំងលើ	ឃុំតាឯក	ស្រុកខ្សាច់កណ្តាល
៣-	លោក តុល អៀវ	មេភូមិ ទ្រាំងក្រោម	ឃុំតាឯក	ស្រុកខ្សាច់កណ្តាល
៤-	លោក ពីង ថូ	មេភូមិ លើ	ឃុំកោះចូរ៉ាម	ស្រុកខ្សាច់កណ្តាល
៥-	លោក គន់ គង់	មេភូមិ កណ្តាល	ឃុំកោះចូរ៉ាម	ស្រុកខ្សាច់កណ្តាល
៦-	លោក ម៉ៅ សម្បត្តិ	មេភូមិ ត្បូង	ឃុំកោះចូរ៉ាម	ស្រុកខ្សាច់កណ្តាល
៧-	លោក ភី ហុកស្រេង	មេភូមិ ក្រោម	ឃុំកោះចូរ៉ាម	ស្រុកខ្សាច់កណ្តាល
៨-	លោក ឡុង គឹមអេង	មេភូមិ ស្វា	ឃុំស្វាយរមៀត	ស្រុកខ្សាច់កណ្តាល
៩-	លោក សេង ម៉េងសៀង	មេភូមិ ស្វាយរមៀត	ឃុំស្វាយរមៀត	ស្រុកខ្សាច់កណ្តាល
១០-	លោក លាង ជៀប	មេភូមិ ព្រែកតាខែន	ឃុំស្វាយរមៀត	ស្រុកខ្សាច់កណ្តាល
១១-	លោក សេង លន់	មេភូមិ ឈើទាល	ឃុំស្វាយរមៀត	ស្រុកខ្សាច់កណ្តាល

១២-	លោក	ឃួន ហុក	មេភូមិ កណ្ដាល	ឃុំស្វាយរមៀត	ស្រុកខ្សាច់កណ្ដាល
១៣-	លោក	អោ មាន	មេភូមិ ស្វាយដំណាក់	ឃុំស្វាយរមៀត	ស្រុកខ្សាច់កណ្ដាល
១៤-	លោក	កន គីម	មេភូមិ ព្រែកតាបែន	ឃុំព្រះប្រសប់	ស្រុកខ្សាច់កណ្ដាល
១៥-	លោក	ហ៊ុន អួន	មេភូមិ ព្រះប្រសប់	ឃុំព្រះប្រសប់	ស្រុកខ្សាច់កណ្ដាល
១៦-	លោក	អៀ ស្រេង	មេភូមិ ព្រែកតាទន់	ឃុំព្រះប្រសប់	ស្រុកខ្សាច់កណ្ដាល
១៧-	លោក	សំ ស្រួច	មេភូមិ ទេពមន្ត្រី	ឃុំព្រះប្រសប់	ស្រុកខ្សាច់កណ្ដាល
១៨-	លោក	យូ អុន	មេភូមិ ព្រែកតាគង់	ឃុំព្រែកតាមាក់	ស្រុកខ្សាច់កណ្ដាល
១៩-	លោក	ខៀវ ចួន	មេភូមិ កំពង់ដីរ	ឃុំព្រែកតាមាក់	ស្រុកខ្សាច់កណ្ដាល
២០-	លោក	វ៉ុង វ៉ាន	មេភូមិ ក្លុង	ឃុំព្រែកតាមាក់	ស្រុកខ្សាច់កណ្ដាល
២១-	លោក	ឈីវ ម៉េងយូ	មេភូមិ ព្រែកតាមាក់	ឃុំព្រែកតាមាក់	ស្រុកខ្សាច់កណ្ដាល
២២-	លោក	ភុល ជឿន	មេភូមិ ស្វាយអាត់លើ	ឃុំព្រែកតាមាក់	ស្រុកខ្សាច់កណ្ដាល
២៣-	លោក	យុន យ៉ាង	មេភូមិ ស្វាយអាត់កណ្ដាល	ឃុំព្រែកតាមាក់	ស្រុកខ្សាច់កណ្ដាល
២៤-	លោក	ប៊ិន ខ្មៅ	មេភូមិ ស្វាយអាត់ក្រោម	ឃុំព្រែកតាមាក់	ស្រុកខ្សាច់កណ្ដាល
២៥-	លោក	នុត ឡុង	មេភូមិ បឹងក្រចាប់ជើង	ឃុំព្រែកតាមាក់	ស្រុកខ្សាច់កណ្ដាល
២៦-	លោក	អួន ងួន	មេភូមិ បឹងក្រចាប់ត្បូង	ឃុំព្រែកតាមាក់	ស្រុកខ្សាច់កណ្ដាល
២៧-	លោក	លាង មួល	មេភូមិ អន្ទុង	ឃុំព្រែកតាមាក់	ស្រុកខ្សាច់កណ្ដាល
២៨-	លោក	យិន គង់	មេភូមិ អញ្ចែងលើ	ឃុំពុកឫស្សី	ស្រុកខ្សាច់កណ្ដាល
២៩-	លោក	សាត់ អុន	មេភូមិ អញ្ចែងក្រោម	ឃុំពុកឫស្សី	ស្រុកខ្សាច់កណ្ដាល
៣០-	លោក	ជាម ឈន	មេភូមិ ព្រួចសើច	ឃុំពុកឫស្សី	ស្រុកខ្សាច់កណ្ដាល
៣១-	លោក	អោក អួន	មេភូមិ ពុកឫស្សី	ឃុំពុកឫស្សី	ស្រុកខ្សាច់កណ្ដាល
៣២-	លោក	ម៉ម ពៅ	មេភូមិ ពុកឫស្សីកណ្ដាល	ឃុំពុកឫស្សី	ស្រុកខ្សាច់កណ្ដាល
៣៣-	លោក	សួន សួរ	មេភូមិ ពុកឫស្សីក្រោម	ឃុំពុកឫស្សី	ស្រុកខ្សាច់កណ្ដាល
៣៤-	លោក	ចិក ប៉យ	មេភូមិ ឃ្លាំងមឿងជើង	ឃុំព្រែកអំពិល	ស្រុកខ្សាច់កណ្ដាល
៣៥-	លោក	យុន យឹម	មេភូមិ ឃ្លាំងមឿងត្បូង	ឃុំព្រែកអំពិល	ស្រុកខ្សាច់កណ្ដាល
៣៦-	លោក	សុខ សឿន	មេភូមិ ព្រែកក្របៅទី១	ឃុំព្រែកអំពិល	ស្រុកខ្សាច់កណ្ដាល
៣៧-	លោក	អ៊ឹម ម៉េត	មេភូមិ ព្រែកក្របៅទី២	ឃុំព្រែកអំពិល	ស្រុកខ្សាច់កណ្ដាល
៣៨-	លោក	អោក រស់	មេភូមិ ព្រែកក្របៅទី៣	ឃុំព្រែកអំពិល	ស្រុកខ្សាច់កណ្ដាល
៣៩-	លោក	ហឿន ហុន	មេភូមិ ព្រែកអួនហែម	ឃុំព្រែកអំពិល	ស្រុកខ្សាច់កណ្ដាល
៤០-	លោក	ណាវ វន	មេភូមិ ព្រែកអំពិល	ឃុំព្រែកអំពិល	ស្រុកខ្សាច់កណ្ដាល
៤១-	លោក	ញ៉ិល ចាច	មេភូមិ ក្ដីចាស់	ឃុំព្រែកល្ហុង	ស្រុកខ្សាច់កណ្ដាល
៤២-	លោក	ធីន ផុន	មេភូមិ ព្រែកតាទេព	ឃុំព្រែកល្ហុង	ស្រុកខ្សាច់កណ្ដាល
៤៣-	លោក	ផ្លុង ចុល	មេភូមិ ព្រែកល្ហុង	ឃុំព្រែកល្ហុង	ស្រុកខ្សាច់កណ្ដាល
៤៤-	លោក	អេង សុខ	មេភូមិ ព្រែកចោង	ឃុំព្រែកល្ហុង	ស្រុកខ្សាច់កណ្ដាល
៤៥-	លោក	ស្រី វិត	មេភូមិ ព្រែកបង្កង	ឃុំព្រែកតាកូវ	ស្រុកខ្សាច់កណ្ដាល

៤៦-	លោក ភួង សុខ	មេភូមិ ព្រែកតាកូវ	ឃុំព្រែកតាកូវ	ស្រុកខ្សាច់កណ្ដាល
៤៧-	លោក អឿ សំអិន	មេភូមិ ព្រែកល្វា	ឃុំព្រែកតាកូវ	ស្រុកខ្សាច់កណ្ដាល
៤៨-	លោក ភួង ផន	មេភូមិ ឋារាជ	ឃុំស្វាយជ្រំ	ស្រុកខ្សាច់កណ្ដាល
៤៩-	លោក អន យ៉ុង	មេភូមិ ស្វាយជ្រំ	ឃុំស្វាយជ្រំ	ស្រុកខ្សាច់កណ្ដាល
៥០-	លោក រស់ ឆន	មេភូមិ លើ	ឃុំស្វាយជ្រំ	ស្រុកខ្សាច់កណ្ដាល
៥១-	លោក លាស់ ឈួន	មេភូមិ កោះតូច	ឃុំកោះឧកញ៉ាតី	ស្រុកខ្សាច់កណ្ដាល
៥២-	លោក យាន ចុន	មេភូមិ ក្បាលកោះ	ឃុំកោះឧកញ៉ាតី	ស្រុកខ្សាច់កណ្ដាល
៥៣-	លោក ម៉ិល មឿន	មេភូមិ កណ្ដាលកោះ	ឃុំកោះឧកញ៉ាតី	ស្រុកខ្សាច់កណ្ដាល
៥៤-	លោក ស៊ុំ តោ	មេភូមិ ខ្ពប	ឃុំកោះឧកញ៉ាតី	ស្រុកខ្សាច់កណ្ដាល
៥៥-	លោក ឈុន សារី	មេភូមិ ចុងកោះ	ឃុំកោះឧកញ៉ាតី	ស្រុកខ្សាច់កណ្ដាល
៥៦-	លោក សំ ម៉ៅ	មេភូមិ ទ្រា	ឃុំរកាជន្លឹង	ស្រុកខ្សាច់កណ្ដាល
៥៧-	លោក សំ ហួន	មេភូមិ ជន្លឹង	ឃុំរកាជន្លឹង	ស្រុកខ្សាច់កណ្ដាល
៥៨-	លោក អ៊ឹម សុត	មេភូមិ រកាទី១	ឃុំរកាជន្លឹង	ស្រុកខ្សាច់កណ្ដាល
៥៩-	លោក ពេញ ស្រៀន	មេភូមិ រកាទី២	ឃុំរកាជន្លឹង	ស្រុកខ្សាច់កណ្ដាល
៦០-	លោក យិន សួង	មេភូមិ តាំងឫស្សី	ឃុំរកាជន្លឹង	ស្រុកខ្សាច់កណ្ដាល
៦១-	លោក ហ៊ុន ប៊ុន	មេភូមិ ជ័យធំ	ឃុំជ័យធំ	ស្រុកខ្សាច់កណ្ដាល
៦២-	លោក ឃុត សំ	មេភូមិ ជ័យតូច	ឃុំជ័យធំ	ស្រុកខ្សាច់កណ្ដាល
៦៣-	លោក សួន សៅ	មេភូមិ តាគាត់លិច	ឃុំជ័យធំ	ស្រុកខ្សាច់កណ្ដាល
៦៤-	លោក លឹម អាន	មេភូមិ តាគាត់កើត	ឃុំជ័យធំ	ស្រុកខ្សាច់កណ្ដាល
៦៥-	លោក ខាត់ យ៉ាត	មេភូមិ ជ្រៃលាស់	ឃុំជ័យធំ	ស្រុកខ្សាច់កណ្ដាល
៦៦-	លោក សេក ឌឹម	មេភូមិ ព្រែកថ្មី	ឃុំជ័យធំ	ស្រុកខ្សាច់កណ្ដាល
៦៧-	លោក ឈុំ ឆន	មេភូមិ សន្ទុង	ឃុំសន្ទុង	ស្រុកខ្សាច់កណ្ដាល
៦៨-	លោក ខៅ ខុន	មេភូមិ ឈូក	ឃុំសន្ទុង	ស្រុកខ្សាច់កណ្ដាល
៦៩-	លោក ថ្វាង ឆន	មេភូមិ ថ្មី	ឃុំសន្ទុង	ស្រុកខ្សាច់កណ្ដាល
៧០-	លោក ពិន ឡូញ	មេភូមិ កណ្ដាល	ឃុំសន្ទុង	ស្រុកខ្សាច់កណ្ដាល
៧១-	លោក មាច វីន	មេភូមិ ព្រៃធំ	ឃុំសន្ទុង	ស្រុកខ្សាច់កណ្ដាល
៧២-	លោក ឡុច ប្រាក់	មេភូមិ ដុល	ឃុំសន្ទុង	ស្រុកខ្សាច់កណ្ដាល
៧៣-	លោក ស៊ិន យ៉ន	មេភូមិ ព្រៃចាស់	ឃុំវិហារសួគ៌	ស្រុកខ្សាច់កណ្ដាល
៧៤-	លោក នុត ទិន	មេភូមិ សេដា	ឃុំវិហារសួគ៌	ស្រុកខ្សាច់កណ្ដាល
៧៥-	លោក ស្រុន ខន	មេភូមិ វិហារសួគ៌ជើង	ឃុំវិហារសួគ៌	ស្រុកខ្សាច់កណ្ដាល
៧៦-	លោក ចាំង សេង	មេភូមិ វិហារសួគ៌ត្បូង	ឃុំវិហារសួគ៌	ស្រុកខ្សាច់កណ្ដាល
៧៧-	លោក ចយ ជឿន	មេភូមិ ព្រៃធំ	ឃុំវិហារសួគ៌	ស្រុកខ្សាច់កណ្ដាល
៧៨-	លោក អ៊ុន អុន	មេភូមិ តាកែវទី២	ឃុំវិហារសួគ៌	ស្រុកខ្សាច់កណ្ដាល
៧៩-	លោក ឈឿន ឆុន	មេភូមិ តាកែវទី១	ឃុំវិហារសួគ៌	ស្រុកខ្សាច់កណ្ដាល

៨០-	លោក ជា ហុន	មេភូមិ ស្វាយមាស	ឃុំវិហារសួគ៌	ស្រុកខ្សាច់កណ្ដាល
៨១-	លោក អ៊ុន អែម	មេភូមិ ស៊ីធរកើត	ឃុំស៊ីធរ	ស្រុកខ្សាច់កណ្ដាល
៨២-	លោក ហង់ សឿន	មេភូមិ ស៊ីធរលិច	ឃុំស៊ីធរ	ស្រុកខ្សាច់កណ្ដាល
៨៣-	លោក ហេង ផេង	មេភូមិ ទួលពង្រ	ឃុំស៊ីធរ	ស្រុកខ្សាច់កណ្ដាល
៨៤-	លោក យ៉ាត យ៉ុន	មេភូមិ ព្រៃទាំង	ឃុំស៊ីធរ	ស្រុកខ្សាច់កណ្ដាល
៨៥-	លោក យោន យុន	មេភូមិ មេបាន់	ឃុំស៊ីធរ	ស្រុកខ្សាច់កណ្ដាល
៨៦-	លោក អ៊ឹម ខ្វាត់	មេភូមិ កំពង់ល្វា	ឃុំស៊ីធរ	ស្រុកខ្សាច់កណ្ដាល
៨៧-	លោក ហ៊ិន ហួន	មេភូមិ កំពង់ចំលង	ឃុំកំពង់ចំលង	ស្រុកខ្សាច់កណ្ដាល
៨៨-	លោក លេញ លន	មេភូមិ ត្បូងដីរ	ឃុំកំពង់ចំលង	ស្រុកខ្សាច់កណ្ដាល
៨៩-	លោក មិ ចឹម	មេភូមិ ព្រែកដំបង	ឃុំកំពង់ចំលង	ស្រុកខ្សាច់កណ្ដាល
៩០-	លោក លី យាន	មេភូមិ ជ្រោយខ្សាច់	ឃុំបាក់ដាវ	ស្រុកខ្សាច់កណ្ដាល
៩១-	លោក សោម សារិទ្ធី	មេភូមិ បាក់ដាវលើ	ឃុំបាក់ដាវ	ស្រុកខ្សាច់កណ្ដាល
៩២-	លោក ឈិន ឆេង	មេភូមិ បាក់ដាវក្រោម	ឃុំបាក់ដាវ	ស្រុកខ្សាច់កណ្ដាល
៩៣-	លោក ឯម ផាន់	មេភូមិ ព្រែកផ្អែក	ឃុំបាក់ដាវ	ស្រុកខ្សាច់កណ្ដាល
៩៤-	លោក អៀន គឹមឆួន	ជំនួយការ ឃុំតាឯក		ស្រុកខ្សាច់កណ្ដាល
៩៥-	លោក ម៉ើ អ៊ឹម	ជំនួយការ ឃុំកោះចូរ៉ាម		ស្រុកខ្សាច់កណ្ដាល
៩៦-	លោក គា ម៉េងឃី	ជំនួយការ ឃុំស្វាយរមៀត		ស្រុកខ្សាច់កណ្ដាល
៩៧-	លោក តោ យ៉ុន	ជំនួយការ ឃុំព្រះប្រសប់		ស្រុកខ្សាច់កណ្ដាល
៩៨-	លោក ញ៉ែម ឡុន	ជំនួយការ ឃុំព្រែកតាមាក់		ស្រុកខ្សាច់កណ្ដាល
៩៩-	លោក សន ស៊ីន	ជំនួយការ ឃុំពុកឬស្សី		ស្រុកខ្សាច់កណ្ដាល
១០០-	លោក វ័ន្ត ប៉េង	ជំនួយការ ឃុំព្រែកអំពិល		ស្រុកខ្សាច់កណ្ដាល
១០១-	លោក ពីន ខុន	ជំនួយការ ឃុំព្រែកលួង		ស្រុកខ្សាច់កណ្ដាល
១០២-	លោកស្រី យ៉ុម យៀង	ជំនួយការ ឃុំព្រែកតាកូវ		ស្រុកខ្សាច់កណ្ដាល
១០៣-	លោក ចក់ ឆន	ជំនួយការ ឃុំស្វាយជ្រំ		ស្រុកខ្សាច់កណ្ដាល
១០៤-	លោក សេង ឈាន	ជំនួយការ ឃុំកោះឧកញ៉ាតី		ស្រុកខ្សាច់កណ្ដាល
១០៥-	លោក សែន សឿន	ជំនួយការ ឃុំរកាជន្លឹង		ស្រុកខ្សាច់កណ្ដាល
១០៦-	លោក យ៉ែម យ៉ុន	ជំនួយការ ឃុំជ័យធំ		ស្រុកខ្សាច់កណ្ដាល
១០៧-	លោក ប៊ិច សុខ	ជំនួយការ ឃុំសន្លុង		ស្រុកខ្សាច់កណ្ដាល
១០៨-	លោក មាស លន់	ជំនួយការ ឃុំវិហារសួគ៌		ស្រុកខ្សាច់កណ្ដាល
១០៩-	លោក ចិន គឹមហួន	ជំនួយការ ឃុំស៊ីធរ		ស្រុកខ្សាច់កណ្ដាល
១១០-	លោក កង គាន	ជំនួយការ ឃុំកំពង់ចំលង		ស្រុកខ្សាច់កណ្ដាល
១១១-	លោក សៀង សុខ	ជំនួយការ ឃុំបាក់ដាវ		ស្រុកខ្សាច់កណ្ដាល

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមេសា ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា១ និង មាត្រា២*
- *រាជកិច្ច ✓*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៨៨ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ មេដាយមាសការងារ ជូនដល់លោកមេឃុំ ក្នុងខេត្តកណ្តាល ចំនួន ១៤រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចកន្លងមក ដូចមានរាយនាមខាងក្រោម :

១-	លោក ចាត់ អ៊ែល	មេឃុំ កោះផាច់	ស្រុកមុខកំពូល
២-	លោក ញឹក ស៊ីផុន	មេឃុំ ពាក់ខែង	ស្រុកមុខកំពូល
៣-	លោក ឡុង ផា	មេឃុំ ព្រែកអញ្ចាញ	ស្រុកមុខកំពូល
៤-	លោក ពេក ស៊ុម	មេឃុំ ឬស្សីជ្រោយ	ស្រុកមុខកំពូល
៥-	លោក ខេត ណាម	មេឃុំ ព្រែកដំបង	ស្រុកមុខកំពូល
៦-	លោក ម៉ែន ស៊ុំ	មេឃុំ រការកោងទី១	ស្រុកមុខកំពូល
៧-	លោក ហួង ឈិន	មេឃុំ រការកោងទី២	ស្រុកមុខកំពូល
៨-	លោក តាំ គីប	មេឃុំ ស្វាយអំពារ	ស្រុកមុខកំពូល
៩-	លោក មាស ផល្លី	មេឃុំ សំបួរមាស	ស្រុកមុខកំពូល
១០-	លោក ហ៊ីង សឿន	មេឃុំ ដើមមៀន	ស្រុកតាខ្មៅ

១១- លោក អេង ផន	មេឃុំ ព្រែកឫស្សី	ស្រុកតាខ្មៅ
១២- លោក សេង យន់	មេឃុំ ព្រែកហូរ	ស្រុកតាខ្មៅ
១៣- លោក យ៉ារ៉ មៀង	មេឃុំ កំពង់សំណាញ់	ស្រុកតាខ្មៅ
១៤- លោក ខេន សុភន	មេឃុំ តាខ្មៅ	ស្រុកតាខ្មៅ
១៥- លោក ប៊ុក ហ៊ុន	មេឃុំ កោះធំ"ក"	ស្រុកកោះធំ
១៦- លោក លឹម អ៊ូ	មេឃុំ កោះធំ"ខ"	ស្រុកកោះធំ
១៧- លោក ហ៊ោង ផា	មេឃុំ ព្រែកថ្មី	ស្រុកកោះធំ
១៨- លោក លន ហោ	មេឃុំ ព្រែកស្ដី	ស្រុកកោះធំ
១៩- លោក អ៊ុក ស្រ៊ន	មេឃុំ សំពៅពូន	ស្រុកកោះធំ
២០- លោក ពេជ ពេញ	មេឃុំ ពោធិបាន	ស្រុកកោះធំ
២១- លោក ម៉ារ ធី	មេឃុំ លើកដែក	ស្រុកកោះធំ
២២- លោក ម៉ីង ហ៊ាង	មេឃុំ កំពង់កុង	ស្រុកកោះធំ
២៣- លោក កែវ រ៉ា	មេឃុំ ជ្រោយតាកែវ	ស្រុកកោះធំ
២៤- លោក សែប ស្រួល	មេឃុំ ឈើខ្មៅ	ស្រុកកោះធំ
២៥- លោក ឡឹង សេង	មេឃុំ ព្រែកជ្រៃ	ស្រុកកោះធំ
២៦- លោក ស៊ុរ៉េ ឌួន	មេឃុំ អរិយក្សត្រ	ស្រុកល្វាឯម
២៧- លោក ប៊ុន សម្បត្តិ	មេឃុំ សារិកាកែវ	ស្រុកល្វាឯម
២៨- លោក ផ្លង ធឿន	មេឃុំ ពាមឧកញ៉ាអុង	ស្រុកល្វាឯម
២៩- លោក សេក ព្រឿង	មេឃុំ កោះរះ	ស្រុកល្វាឯម
៣០- លោក ទិត សុខ	មេឃុំ ថ្មគរ	ស្រុកល្វាឯម
៣១- លោក ចាន់ សាន	មេឃុំ ទឹកឃ្លាំង	ស្រុកល្វាឯម
៣២- លោក ពៅ កែវ	មេឃុំ បឹងគ្រំ	ស្រុកល្វាឯម
៣៣- លោក ចិន ហ៊ន	មេឃុំ ល្វាសរ	ស្រុកល្វាឯម
៣៤- លោក ស៊ួន សុខន	មេឃុំ កោះកែវ	ស្រុកល្វាឯម
៣៥- លោក រស់ សាមិត្ត	មេឃុំ សំបួរ	ស្រុកល្វាឯម
៣៦- លោក នង សំអុល	មេឃុំ ព្រែកឫស្សី	ស្រុកល្វាឯម
៣៧- លោក ប៊ិន សេន	មេឃុំ ភូមិធំ	ស្រុកល្វាឯម
៣៨- លោក ឈ្លាក ជ្រឹង	មេឃុំ ព្រែករៃ	ស្រុកល្វាឯម
៣៩- លោក អ៊ូ សុផាត	មេឃុំ ព្រែកក្មេង	ស្រុកល្វាឯម
៤០- លោក ម៉ែន លន	មេឃុំ ចារ៉ុង	ស្រុកល្វាឯម
៤១- លោក ញឹប អៀន	មេឃុំ តាឯក	ស្រុកខ្សាច់កណ្ដាល
៤២- លោក អ៊ុក រស់	មេឃុំ កោះចូរ៉ាម	ស្រុកខ្សាច់កណ្ដាល
៤៣- លោក ម៉ើស ស៊ីង	មេឃុំ ស្វាយរមៀត	ស្រុកខ្សាច់កណ្ដាល
៤៤- លោក ឡូង សៀងគង់	មេឃុំ ព្រះប្រសប់	ស្រុកខ្សាច់កណ្ដាល

៤៥-	លោក យ៉ាន់ ឆុន	មេឃុំ ព្រែកតាមាក់	ស្រុកខ្សាច់កណ្ដាល
៤៦-	លោក អេង យឺន	មេឃុំ ពុកឫស្សី	ស្រុកខ្សាច់កណ្ដាល
៤៧-	លោក យន់ សារឿន	មេឃុំ ព្រែកអំពិល	ស្រុកខ្សាច់កណ្ដាល
៤៨-	លោក ហង់ ភាង	មេឃុំ ព្រែកល្ហុង	ស្រុកខ្សាច់កណ្ដាល
៤៩-	លោក ព្រួល ស៊ុន	មេឃុំ ព្រែកតាកូវ	ស្រុកខ្សាច់កណ្ដាល
៥០-	លោក ទេព ប៊ុក	មេឃុំ ស្វាយជ្រំ	ស្រុកខ្សាច់កណ្ដាល
៥១-	លោក វ៉ាន់ សុខលី	មេឃុំ កោះឧកញ៉ាតី	ស្រុកខ្សាច់កណ្ដាល
៥២-	លោក ឈោម ឆាយ	មេឃុំ រកាជន្លឹង	ស្រុកខ្សាច់កណ្ដាល
៥៣-	លោក សុខ មុត	មេឃុំ ជ័យធំ	ស្រុកខ្សាច់កណ្ដាល
៥៤-	លោក សរ ហេង	មេឃុំ សន្លុង	ស្រុកខ្សាច់កណ្ដាល
៥៥-	លោក ឧង សេងលី	មេឃុំ វិហារសួគ៌	ស្រុកខ្សាច់កណ្ដាល
៥៦-	លោក ជា លឹម	មេឃុំ ស៊ីធរ	ស្រុកខ្សាច់កណ្ដាល
៥៧-	លោក សាន់ សារ៉េត	មេឃុំ កំពង់ចំលង	ស្រុកខ្សាច់កណ្ដាល
៥៨-	លោក វ៉េង ហួរ	មេឃុំ បាក់ដាវ	ស្រុកខ្សាច់កណ្ដាល
៥៩-	លោក ពេជ ណុំ	មេឃុំ ព្រែកល្ពៅ	ស្រុកពញាឮ
៦០-	លោក កង សែន	មេឃុំ សំរោង	ស្រុកពញាឮ
៦១-	លោក ញឹម ជេដ្ឋ	មេឃុំ ព្រែកតាទែន	ស្រុកពញាឮ
៦២-	លោក រស់ ស្រង់	មេឃុំ ពញាឮ	ស្រុកពញាឮ
៦៣-	លោក ឧង ណារ៉ុង	មេឃុំ កំពង់អុស	ស្រុកពញាឮ
៦៤-	លោក ជា គឹមសេង	មេឃុំ កោះចិន	ស្រុកពញាឮ
៦៥-	លោក មុត ខាន់	មេឃុំ កំពង់ល្ហុង	ស្រុកពញាឮ
៦៦-	លោក ហ៊ុយ យ៉ាន់	មេឃុំ វិហារល្ហុង	ស្រុកពញាឮ
៦៧-	លោក សុខ ដាំ	មេឃុំ ផ្សារដែក	ស្រុកពញាឮ
៦៨-	លោក សែម សុផល	មេឃុំ ភ្នំបាត	ស្រុកពញាឮ
៦៩-	លោក នូ ឡេន	មេឃុំ ទំនប់ធំ	ស្រុកពញាឮ
៧០-	លោក ឆាំ ថា	មេឃុំ ជ្រៃលាស់	ស្រុកពញាឮ
៧១-	លោក ហ៊ុន គឹមហួរ	មេឃុំ ឃ្លាំង	ស្រុកពញាឮ
៧២-	លោក ឌុល សន	មេឃុំ ពញាពន់	ស្រុកពញាឮ
៧៣-	លោក ប៊ិន ឆន្ន	មេឃុំ បែកចាន	ស្រុកអង្គស្នួល
៧៤-	លោក ហ៊ុយ យ៉ែម	មេឃុំ កំបូល	ស្រុកអង្គស្នួល
៧៥-	លោក យ៉ង់ ស៊ីថុល	មេឃុំ កន្ទោក	ស្រុកអង្គស្នួល
៧៦-	លោក មឿង អួន	មេឃុំ បឹងធំ	ស្រុកអង្គស្នួល
៧៧-	លោក ម៉ៅ លី	មេឃុំ ក្រាំងម្កាក់	ស្រុកអង្គស្នួល
៧៨-	លោក ទូច ផុន	មេឃុំ ព្រៃពួច	ស្រុកអង្គស្នួល

៧៩-	លោក ងួន ស្រួយ	មេឃុំ លំហាច	ស្រុកអង្គស្នួល
៨០-	លោក ឡុង ង៉ែត	មេឃុំ ដំណាក់អំពិល	ស្រុកអង្គស្នួល
៨១-	លោក ពេញ ផល់	មេឃុំ ពើក	ស្រុកអង្គស្នួល
៨២-	លោក យិន យ៉េន	មេឃុំ ឆក់ឈើនាង	ស្រុកអង្គស្នួល
៨៣-	លោក សុខ សឿន	មេឃុំ សំរោងលើ	ស្រុកអង្គស្នួល
៨៤-	លោក យន់ សុខុម	មេឃុំ ទួលពេជ្រ	ស្រុកអង្គស្នួល
៨៥-	លោក សាន់ ចិន	មេឃុំ ម្កាក់	ស្រុកអង្គស្នួល
៨៦-	លោក ម៉ាង ស្រី	មេឃុំ ពន្សាំង	ស្រុកអង្គស្នួល
៨៧-	លោក សៀ អៀវ	មេឃុំ ស្នោរ	ស្រុកអង្គស្នួល
៨៨-	លោក យឹម ហៃ	មេឃុំ ឪឡោក	ស្រុកអង្គស្នួល
៨៩-	លោក ម៉ៅ ភឿន	មេឃុំ កោះអន្លង់ចិន	ស្រុកស្អាង
៩០-	លោក អឿង គង្គ	មេឃុំ ស្វាយរលំ	ស្រុកស្អាង
៩១-	លោក អ៊ុំ ឡៀង	មេឃុំ សិត្បូ	ស្រុកស្អាង
៩២-	លោក ឈឿង ង្វួ	មេឃុំ រកាខ្ពស់	ស្រុកស្អាង
៩៣-	លោក ទឹម វង់	មេឃុំ ព្រែកគយ	ស្រុកស្អាង
៩៤-	លោក ជី ស្រី	មេឃុំ ទឹកវិល	ស្រុកស្អាង
៩៥-	លោក ឆឹង មុំ	មេឃុំ កោះខែល	ស្រុកស្អាង
៩៦-	លោក នៅ សំប៉ូរ	មេឃុំ ព្រែកអំបិល	ស្រុកស្អាង
៩៧-	លោក ទួន សឿន	មេឃុំ ស្វាយប្រទាល	ស្រុកស្អាង
៩៨-	លោក ហ៊ាង ហៅ	មេឃុំ ត្រើយស្លា	ស្រុកស្អាង
៩៩-	លោក ហ៊ាក កាន់	មេឃុំ តាលន់	ស្រុកស្អាង
១០០-	លោក សុក ប៊ុល	មេឃុំ ខ្ពប	ស្រុកស្អាង
១០១-	លោក ឌុច កាក់	មេឃុំ ប្រាសាទ	ស្រុកស្អាង
១០២-	លោក ឯម ផុន	មេឃុំ កោះខ្សាច់ទន្លា	ស្រុកស្អាង
១០៣-	លោក ម៉ុង ទុយ	មេឃុំ ស្អាងភ្នំ	ស្រុកស្អាង
១០៤-	លោក ស្វរ ហេង	មេឃុំ ក្រាំងយ៉ូវ	ស្រុកស្អាង
១០៥-	លោក ចិន ម៉េង	មេឃុំ រកាំងកែន	ស្រុកកណ្ដាលស្ទឹង
១០៦-	លោក សាន ផុន	មេឃុំ រកា	ស្រុកកណ្ដាលស្ទឹង
១០៧-	លោក អ៊ាម ង៉ាង	មេឃុំ ដើមឫស	ស្រុកកណ្ដាលស្ទឹង
១០៨-	លោក សេក សុត	មេឃុំ អន្លង់រអៀត	ស្រុកកណ្ដាលស្ទឹង
១០៩-	លោក ញ៉ែម ញឹម	មេឃុំ ត្រពាំងវែង	ស្រុកកណ្ដាលស្ទឹង
១១០-	លោក ថួង ទិល	មេឃុំ ពៀង	ស្រុកកណ្ដាលស្ទឹង
១១១-	លោក រស់ គន	មេឃុំ ទ្រា	ស្រុកកណ្ដាលស្ទឹង
១១២-	លោក ឈឹម មន	មេឃុំ ព្រែករកា	ស្រុកកណ្ដាលស្ទឹង

១១៣-	លោក ណៃ ចាន់ឌី	មេឃុំ បឹងខ្សាង	ស្រុកកណ្ដាលស្ទឹង
១១៤-	លោក គី ទៀង	មេឃុំ ព្រែកស្លែង	ស្រុកកណ្ដាលស្ទឹង
១១៥-	លោក សរ ចាន់ភីរុណ	មេឃុំ អំពៅព្រៃ	ស្រុកកណ្ដាលស្ទឹង
១១៦-	លោក ហ៊ុយ សុង	មេឃុំ សៀមរាប	ស្រុកកណ្ដាលស្ទឹង
១១៧-	លោក ហេង ចាន់	មេឃុំ កណ្ដោក	ស្រុកកណ្ដាលស្ទឹង
១១៨-	លោក គង់ ផារ៉ា	មេឃុំ ជើងកើប	ស្រុកកណ្ដាលស្ទឹង
១១៩-	លោក ម៉ិច ប៊ុនឡុង	មេឃុំ ព្រះពុទ្ធមេឃុំ រលួស	ស្រុកកណ្ដាលស្ទឹង
១២០-	លោក គឹប ហ៊ន	មេឃុំ ព្រែកកំពឹស	ស្រុកកណ្ដាលស្ទឹង
១២១-	លោក មុំ ស៊ីម	មេឃុំ ស្ពានថ្ម	ស្រុកកណ្ដាលស្ទឹង
១២២-	លោក ខៀវ ចេង	មេឃុំ ទៀន	ស្រុកកណ្ដាលស្ទឹង
១២៣-	លោក អ៊ូ នួន	មេឃុំ គងនយ	ស្រុកកណ្ដាលស្ទឹង
១២៤-	លោក អ៊ិន ឆុន	មេឃុំ បារគូ	ស្រុកកណ្ដាលស្ទឹង
១២៥-	លោក សុន សឿន	មេឃុំ គោកត្រប់	ស្រុកកណ្ដាលស្ទឹង
១២៦-	លោក មោក ស៊ឹម	មេឃុំ ថ្មី	ស្រុកកណ្ដាលស្ទឹង
១២៧-	លោក ម៉ៅ ម៉ុន	មេឃុំ កំពង់ភ្នំ	ស្រុកកណ្ដាលស្ទឹង
១២៨-	លោក សួន ជិន	មេឃុំ ព្រែកទន្លាប់	ស្រុកលើកដែក
១២៩-	លោក ធី សារី	មេឃុំ ព្រែកដាច់	ស្រុកលើកដែក
១៣០-	លោក គង់ យ៉េត	មេឃុំ ពាមរាំង	ស្រុកលើកដែក
១៣១-	លោក ហ៊ាង ហាក់	មេឃុំ ឧបអាទាវ	ស្រុកលើកដែក
១៣២-	លោក ឡី សាយ	មេឃុំ សណ្ដារ	ស្រុកលើកដែក
១៣៣-	លោក ម៉ើ ស្រាង	មេឃុំ ភ្នមសំណារ	ស្រុកលើកដែក
១៣៤-	លោក អ៊ាង សាគុណ	មេឃុំ វាលស្បូវ	ស្រុកលើកដែក
១៣៥-	លោក អ៊ុយ សាត	មេឃុំ ព្រែកឯង	ស្រុកកៀនស្វាយ
១៣៦-	លោក នេត សារ៉ែន	មេឃុំ ក្បាលកោះ	ស្រុកកៀនស្វាយ
១៣៧-	លោក យី សុង	មេឃុំ ភូមិធំ	ស្រុកកៀនស្វាយ
១៣៨-	លោក តុប ហ៊ឹ	មេឃុំ គគីរ	ស្រុកកៀនស្វាយ
១៣៩-	លោក ប៉ែន វុធ	មេឃុំ ដីឥដ្ឋ	ស្រុកកៀនស្វាយ
១៤០-	លោក យឹម យឿន	មេឃុំ បន្ទាយដែក	ស្រុកកៀនស្វាយ
១៤១-	លោក ធិន ណើម	មេឃុំ សំរោងធំ	ស្រុកកៀនស្វាយ
១៤២-	លោក មេព ឈួន	មេឃុំ គគីរធំ	ស្រុកកៀនស្វាយ
១៤៣-	លោក ចាន់ ធួ	មេឃុំ ព្រែកថ្មី	ស្រុកកៀនស្វាយ
១៤៤-	លោក ជា ស្រួយ	មេឃុំ ឈើទាល	ស្រុកកៀនស្វាយ
១៤៥-	លោក ពាង យឿន	មេឃុំ កំពង់ស្វាយ	ស្រុកកៀនស្វាយ
១៤៦-	លោក សាយ ភឿន		ស្រុកកៀនស្វាយ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ០៣ ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>**កន្លែងទទួល**</u> :

- _ក្រសួងព្រះបរមរាជវាំង
- _អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- _អគ្គលេខាធិការដ្ឋានរដ្ឋសភា
- _ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- _ដូចមាត្រា១ និង មាត្រា២
- _រាជកិច្ច ✓
  - _ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១៧៩...អនក្រ.បក

អនុក្រឹត្យ

ស្ដីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

<u>**សម្រេច**</u>

មាត្រា១ : ត្រូវបានបំពាក់ **មេដាយប្រាក់ការងារ** ជូនដល់អស់លោកជំទប់ ក្នុងខេត្តកណ្ដាល ចំនួន ៤៣៣ រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចកន្លងមក ដូចមានរាយនាមខាងក្រោម :

១- លោក អ៊ូ សុធីម	ជំទប់ទី១ ឃុំដោះដាច់	ស្រុកមុខកំពូល
២- លោក កេត ប៉េត	ជំទប់ទី២ ឃុំដោះដាច់	ស្រុកមុខកំពូល
៣- លោក ឯក យ៉ាន់	ជំទប់ទី១ ឃុំបាក់ខែង	ស្រុកមុខកំពូល
៤- លោក ងួន អួន	ជំទប់ទី២ ឃុំបាក់ខែង	ស្រុកមុខកំពូល
៥- លោក ភ្លាន់ ឈឿន	ជំទប់ទី១ ឃុំព្រែកអញ្ចាញ	ស្រុកមុខកំពូល
៦- លោក ឯម រស់	ជំទប់ទី៣ ឃុំព្រែកអញ្ចាញ	ស្រុកមុខកំពូល
៧- លោក អ៊ៅ ចាន់	ជំទប់ទី១ ឃុំឫស្សីជ្រោយ	ស្រុកមុខកំពូល
៨- លោក ហោ សេង	ជំទប់ទី២ ឃុំឫស្សីជ្រោយ	ស្រុកមុខកំពូល

៩-	លោក ស្វាយ ស៊ូ	ជំទប់ទី៣	ឃុំឫស្សីជ្រោយ	ស្រុកមុខកំពូល
១០-	លោក ស៊ុយ សៃ	ជំទប់ទី១	ឃុំព្រែកដំបង	ស្រុកមុខកំពូល
១១-	លោកស្រី យឹម ស៊ីន	ជំទប់ទី២	ឃុំព្រែកដំបង	ស្រុកមុខកំពូល
១២-	លោក សៀ ង្វន	ជំទប់ទី៣	ឃុំព្រែកដំបង	ស្រុកមុខកំពូល
១៣-	លោក លឹម សុងហី	ជំទប់ទី១	ឃុំរកាកោងទី១	ស្រុកមុខកំពូល
១៤-	លោក អ៊ុក សាមី	ជំទប់ទី២	ឃុំរកាកោងទី១	ស្រុកមុខកំពូល
១៥-	លោក ជំ ឧន	ជំទប់ទី៣	ឃុំរកាកោងទី១	ស្រុកមុខកំពូល
១៦-	លោក កង សារី	ជំទប់ទី១	ឃុំរកាកោងទី២	ស្រុកមុខកំពូល
១៧-	លោក ចាន់ ឧន	ជំទប់ទី២	ឃុំរកាកោងទី២	ស្រុកមុខកំពូល
១៨-	លោក ម៉ាន នៅ	ជំទប់ទី៣	ឃុំរកាកោងទី២	ស្រុកមុខកំពូល
១៩-	លោក នន់ សំបួរ	ជំទប់ទី១	ឃុំស្វាយអំពារ	ស្រុកមុខកំពូល
២០-	លោក សោ នៅ	ជំទប់ទី៣	ឃុំស្វាយអំពារ	ស្រុកមុខកំពូល
២១-	លោក ស៊ិន ទឹម	ជំទប់ទី១	ឃុំសំបួរមាស	ស្រុកមុខកំពូល
២២-	លោក មាច ប្រាក់	ជំទប់ទី៣	ឃុំសំបួរមាស	ស្រុកមុខកំពូល
២៣-	លោក សោម ប៊ូ	ជំទប់ទី១	ឃុំព្រែកឫស្សី	ស្រុកតាខ្មៅ
២៤-	លោក ផន ផ្ទុំ	ជំទប់ទី២	ឃុំព្រែកឫស្សី	ស្រុកតាខ្មៅ
២៥-	លោក ប៊ុន ហ៊ុយ	ជំទប់ទី៣	ឃុំព្រែកឫស្សី	ស្រុកតាខ្មៅ
២៦-	លោក ប៊ូ ឆន	ជំទប់ទី១	ឃុំតាខ្មៅ	ស្រុកតាខ្មៅ
២៧-	លោក ស៊ីម ហុង	ជំទប់ទី២	ឃុំតាខ្មៅ	ស្រុកតាខ្មៅ
២៨-	លោក ឯម សុំ	ជំទប់ទី៣	ឃុំតាខ្មៅ	ស្រុកតាខ្មៅ
២៩-	លោក កែវ ម៉ុន	ជំទប់ទី១	ឃុំតាក្តុល	ស្រុកតាខ្មៅ
៣០-	លោក សែម អ៊ីន	ជំទប់ទី២	ឃុំតាក្តុល	ស្រុកតាខ្មៅ
៣១-	លោក យ៉ាង សំអុល	ជំទប់ទី៣	ឃុំតាក្តុល	ស្រុកតាខ្មៅ
៣២-	លោក ហង្ស កុំ	ជំទប់ទី១	ឃុំព្រែកហូរ	ស្រុកតាខ្មៅ
៣៣-	លោកស្រី ម៉ម សុខនី	ជំទប់ទី២	ឃុំព្រែកហូរ	ស្រុកតាខ្មៅ
៣៤-	លោក យូស យ័ន្ត	ជំទប់ទី៣	ឃុំព្រែកហូរ	ស្រុកតាខ្មៅ
៣៥-	លោក ស ទ្រី	ជំទប់ទី១	ឃុំកំពង់សំណាញ់	ស្រុកតាខ្មៅ
៣៦-	លោក ឡាយ ហោ	ជំទប់ទី២	ឃុំកំពង់សំណាញ់	ស្រុកតាខ្មៅ
៣៧-	លោក សឿ យ៉ុន	ជំទប់ទី៣	ឃុំកំពង់សំណាញ់	ស្រុកតាខ្មៅ
៣៨-	លោក អ៊ាន សារិន	ជំទប់ទី១	ឃុំដើមមៀន	ស្រុកតាខ្មៅ
៣៩-	លោក សុខ វុត្ថា	ជំទប់ទី២	ឃុំដើមមៀន	ស្រុកតាខ្មៅ

៤០-	លោក ខន យុន	ជំទប់ទី៣ ឃុំដើមមៀន	ស្រុកតាខ្មៅ
៤១-	លោក ប៉ុល ណៃ	ជំទប់ទី១ ឃុំកោះធំ(ក)	ស្រុកកោះធំ
៤២-	លោក យ៉ែម មាន	ជំទប់ទី១ ឃុំកោះធំ(ខ)	ស្រុកកោះធំ
៤៣-	លោក ហួយ ឃួន	ជំទប់ទី១ ឃុំព្រែកថ្មី	ស្រុកកោះធំ
៤៤-	លោក ហេ ស្រ៊ុយ	ជំទប់ទី១ ឃុំព្រែកស្ដី	ស្រុកកោះធំ
៤៥-	លោក ឈិត ហ៊ាង	ជំទប់ទី១ ឃុំសំពៅពូន	ស្រុកកោះធំ
៤៦-	លោក សាម ម៉េងហ៊	ជំទប់ទី១ ឃុំពោធិបាន	ស្រុកកោះធំ
៤៧-	លោក ង៉ៃ បូណា	ជំទប់ទី១ ឃុំលើកដែក	ស្រុកកោះធំ
៤៨-	លោក ថៅ ឆាយ	ជំទប់ទី១ ឃុំកំពង់កុង	ស្រុកកោះធំ
៤៩-	លោក វន ទីន	ជំទប់ទី១ ឃុំជ្រោយតាកែវ	ស្រុកកោះធំ
៥០-	លោក ស្រ៊ុន ឈី	ជំទប់ទី១ ឃុំឈើខ្មៅ	ស្រុកកោះធំ
៥១-	លោក ឃួន សារ៉ាត	ជំទប់ទី១ ឃុំព្រែកជ្រៃ	ស្រុកកោះធំ
៥២-	លោក ឈន ចិន	ជំទប់ទី២ ឃុំកោះធំ(ក)	ស្រុកកោះធំ
៥៣-	លោក ជ្រឹង ឈាង	ជំទប់ទី២ ឃុំកោះធំ(ខ)	ស្រុកកោះធំ
៥៤-	លោក អ៊ិន ថន	ជំទប់ទី២ ឃុំព្រែកថ្មី	ស្រុកកោះធំ
៥៥-	លោក ចួយ ស្រ៊ុន	ជំទប់ទី២ ឃុំព្រែកស្ដី	ស្រុកកោះធំ
៥៦-	លោក ឡុច ផាន្នី	ជំទប់ទី២ ឃុំសំពៅពូន	ស្រុកកោះធំ
៥៧-	លោក គុប សេងលី	ជំទប់ទី២ ឃុំពោធិបាន	ស្រុកកោះធំ
៥៨-	លោក ភុំ សួស្ដី	ជំទប់ទី២ ឃុំលើកដែក	ស្រុកកោះធំ
៥៩-	លោក ស្រេង យូ	ជំទប់ទី២ ឃុំកំពង់កុង	ស្រុកកោះធំ
៦០-	លោក កុច ម៉េង	ជំទប់ទី២ ឃុំជ្រោយតាកែវ	ស្រុកកោះធំ
៦១-	លោក ថាយ តួន	ជំទប់ទី២ ឃុំឈើខ្មៅ	ស្រុកកោះធំ
៦២-	លោក ចាប ស៊ុយ	ជំទប់ទី២ ឃុំព្រែកជ្រៃ	ស្រុកកោះធំ
៦៣-	លោក ម៉ៅ ម៉េងព្រិល	ជំទប់ទី៣ ឃុំកោះធំ(ខ)	ស្រុកកោះធំ
៦៤-	លោក សំ ហង់	ជំទប់ទី៣ ឃុំកោះធំ(ក)	ស្រុកកោះធំ
៦៥-	លោក អ៊ឹង សាមឿន	ជំទប់ទី៣ ឃុំព្រែកថ្មី	ស្រុកកោះធំ
៦៦-	លោក ហុង ស្រេង	ជំទប់ទី៣ ឃុំព្រែកស្ដី	ស្រុកកោះធំ
៦៧-	លោក អួន អឿន	ជំទប់ទី៣ ឃុំសំពៅពូន	ស្រុកកោះធំ
៦៨-	លោក សំ សារ៉ន	ជំទប់ទី៣ ឃុំពោធិបាន	ស្រុកកោះធំ
៦៩-	លោក ប៊ិញ សុភាព	ជំទប់ទី៣ ឃុំលើកដែក	ស្រុកកោះធំ
៧០-	លោក គឹម ហួរ	ជំទប់ទី៣ ឃុំកំពង់កុង	ស្រុកកោះធំ

៧១-	លោក ម៉ៅ ផុន	ជំទប់ទី៣ ឃុំជ្រោយតាកែវ	ស្រុកកោះធំ
៧២-	លោក យុន រី	ជំទប់ទី៣ ឃុំឈើខ្មៅ	ស្រុកកោះធំ
៧៣-	លោក បៀង អ៊ួ	ជំទប់ទី៣ ឃុំព្រែកជ្រៃ	ស្រុកកោះធំ
៧៤-	លោក ចាន់ ចេង	ជំទប់ទី១ ឃុំអរិយក្សត្រ	ស្រុកល្វាឯម
៧៥-	លោក ពត ណូ	ជំទប់ទី២ ឃុំអរិយក្សត្រ	ស្រុកល្វាឯម
៧៦-	លោក នួន នឿន	ជំទប់ទី៣ ឃុំអរិយក្សត្រ	ស្រុកល្វាឯម
៧៧-	លោក ទុត បូ	ជំទប់ទី១ ឃុំសារិកាកែវ	ស្រុកល្វាឯម
